# ពុទ្ធិកសមាគមខ្មែរវត្តសាន់ហូសេ

The San Jose Cambodian Buddhist Society, Inc.
840 Mervyn's Way, San Jose, CA 95127 Tel: (408)251-4458
WWW.WATTKHMER.ORG

## បុណ្យខួបឆ្នាំទី ២១ នៃពុទ្ធិកសមាគមខ្មែរវត្តសាន់ហូសេ

ជូនអស់លោកពុទ្ធបរិស័ទគ្រប់រូប មានលោកយាយ លោកតាជាដើម បានជ្រាបស្រាប់មកហើយថា ពុទ្ធិកសមាគមខ្មែរវត្តសាន់ហូសេបានប្រតិស្ឋាននូវព្រះពុទ្ធសាសនាអស់បានចំនួន២១ឆ្នាំនេះហើយ ទាំងព្រះភិក្ខុសង្ឃក្តី គណៈកម្មការគ្រប់ជាន់ថ្នាក់ បានរួបរួមគ្នាប្រកបដោយសាមគ្គីធម៌ និងមានសង្គហធម៌យ៉ាងជិតស្និទ្ធ គួរជាទីពេញចិត្ត ។

នៅខួបឆ្នាំទី២១នេះ គណៈកម្មការគ្រប់ជាន់ថ្នាក់ បានប្រារព្ធធ្វើនូវពិធីបុណ្យនេះឡើងដើម្បី :-

១-ទទួលអនុមោទនាត្រេកអរចំពោះសាសនានៃព្រះពុទ្ធជាម្ចាស់ ដែលបានតាំងនៅស្ថិតថេរចិរកាល ចំនួន២១ឆ្នាំមកហើយ ប្រកបដោយជោគជ័យគ្រប់បែបយ៉ាង ។

២-ឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធ នៃបុព្វបុរស-ស្ត្រី ដែលធ្លាប់បានគោរពប្រតិបត្តិតាមសាសនា ហើយដែលបានចាក់បែកចែកឋានទៅហើយនោះផង និងឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធនៃអ្នកមានគុណយើងគ្រប់រូប ដែលបានបាត់បង់ជីវិតដោយបុញ្ញក្ខ័យក្តី កម្មក្ខ័យក្តី និងអាយុក្ខ័យក្តី ព្រមទាំងព្រះសង្ឃរាជ ថានានុក្រម ព្រះភិក្ខុសង្ឃគ្រប់អង្គដែលបានសុគតអនិច្ចកម្ម ទៅហើយនោះផងដែរ ។

៣-ទទួលពរជ័យពីទេវតាឆ្នាំ២០០៨ ដែលត្រូវយាងមកថែរក្សាមនុស្សលោកនេះ និងសូមឱ្យទេវតាគ្រប់ព្រះអង្គ ក្នុងទ្វីបលោកនេះជួយឱ្យពិភពលោកបានសុខសាន្ត ប្រាសចាកសង្គ្រាមគ្រប់បែបយ៉ាង ។

៤-ទទួលអរគុណដល់រដ្ឋាភិបាលសហរដ្ឋ និងប្រជាពលរដ្ឋអាមេរិកាំងទូទៅដែលបានជួយសង្គ្រោះផ្តល់នូវសេចក្តីសុខគ្រប់ប្រការដល់ជនជាតិខ្មែរ និងគ្រប់សញ្ជាតិដែលបានមកជ្រកកោនដើម្បីរស់ក្នុងប្រទេសនេះ ។

- ដូចបានជំរាបខាងលើ គណៈកម្មការគ្រប់ជាន់ថ្នាក់ សូមគោរពអស់លោក សប្បុរស-ពុទ្ធបរិស័ទទាំងចាស់-ក្មេង មេត្តាអញ្ជើញចូលរួមជួយឧបត្ថម្ភគាំទ្រនូវពិធីបុណ្យនេះឱ្យគានផង ដើម្បីត្រួតត្រា កសាងបុណ្យកុសលសំរាប់ធ្វើដំណើរទៅកាន់បរលោក ព្រោះគ្មានអ្វីប្រសើរជាងបុញ្ញកម្មនេះឡើយ ។

កម្មវិធីនេះ និងប្រព្រឹត្តទៅនៅទីកន្លែង និងពេលវេលាដូចមានក្នុងកាលវិភាគខាងក្រោម :-

## កាលបរិច្ឆេទ

-ពិធីបុណ្យធ្វើនៅទីវត្តសាន់ហូសេ 840 Mervyn's Way , San Jose, CA 95127- Tel : (408)251-4458

ថ្ងៃ-ខែ-ឆ្នាំ-:- សៅរ៍ ទី ៥ មករា ២០០៨ ត្រូវនឹងថ្ងៃ ១២ រោច ខែមិគសិរ ពេលល្ងាច និមន្តព្រះសង្ឃចំរើនព្រះបរិត្ត និងថ្ងៃអាទិត្យ ទី ៦ មករា ២០០៨ ត្រូវនឹងថ្ងៃ ១៣ រោច ខែមិគសិរ មានជូនតទៅ :-

ពេលវេលា :-ពីម៉ោង ៨:៣០ ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់ មានជួបជុំអស់លោក លោកស្រី លោកយាយ លោកតា មីង-មា និងពុទ្ធបរិស័ទទូទៅ-នមស្សការ-សមាទានសីល-ព្រះបរិត្តសូត្រ-រាប់បាត្រ-វេរភត្តប្រគេន-អនុមោទនា-បង្សុកូល-ប្រកាសបច្ច័យចំណូលទាំងអស់-ឧទ្ទិសកុសល-ផ្សាយមេត្តា-បត្តិទានគាថា-និងពិសារអាហារថ្ងៃត្រង់ ។ សូមអរគុណជាអតិបរមា ។

ពីការិយាល័យពុទ្ធិកសមាគមខ្មែរវត្តសាន់ហូសេ